ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ទិដ្ឋភាព ១០០

# នៃ

# រដ្ឋាភិបាល សម រង្ស៊ី

ក្រោយពេលឈ្នះឆ្នោតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣

បោះពុម្ពនៅរាជធានីភ្នំពេញ

# សីលធម៌ សច្ចធម៌ យុត្តិធម៌

# គណបក្ស សម រង្ស៊ី

## ជាក្តីសង្ឃឹមរបស់ប្រជារាស្ត្រខ្មែរ

# មាតិកា

ទំព័រ

## I- លទ្ធិប្រជាធិបតេយ្យ យុត្តិធម៌ និងសិទ្ធិមនុស្ស


1- លើកតម្កើងលទ្ធិប្រជាធិបតេយ្យ ........................................ ១

2- យុត្តិធម៌ ........................................ ៣

3- សិទ្ធិសេរីភាព និងសិទ្ធិមនុស្សជាទូទៅ ........................................ ៤

4- សិទ្ធិព្រះសង្ឃ ........................................ ៤

5- សិទ្ធិស្ត្រី ........................................ ៤


## II- សន្តិសុខគ្រប់បែបយ៉ាងសំរាប់ប្រជារាស្ត្រ


1- សន្តិសុខរាងកាយ ........................................ ៥

2- សន្តិសុខស្បៀងអាហារ ........................................ ៦

3- សន្តិសុខក្នុងការប្រើប្រាស់ទំនិញ ........................................ ៧


## III- លើកតម្កើងជីវភាពរស់នៅ


1- ប្រជារាស្ត្រទូទៅ ........................................ ៧

2- ប្រជាកសិករ ........................................ ១០

3- ប្រជានេសាទ ........................................ ១១

4- មន្ត្រីរាជការ គ្រូបង្រៀន ប៉ូលីស-ទាហាន ........................................ ១១

5- កម្មករ និងនិយោជិត ........................................ ១២

6- កម្មករចំការកៅស៊ូ និងម្ចាស់ចំការកៅស៊ូជាលក្ខណៈគ្រួសារ ............ ១៣
7- អាជីវករ និងអ្នកលក់ដូរតូចតាច .............................................. ១៣
8- អ្នករត់ម៉ូតូឌុប និងតាក់ស៊ី ..................................................... ១៤
9- អតីតយុទ្ធជន .......................................................................... ១៤
10- សិស្ស និងនិស្សិត ................................................................. ១៤

## IV- រដ្ឋាភិបាលស្អាតស្អំ ប្រកបដោយប្រសិទ្ធិភាព

1- ប្រឆាំងអំពើពុករលួយ ......................................................... ១៥
2- យុត្តិធម៌សង្គម .................................................................... ១៦
3- អភិបាលកិច្ចល្អ និងសីលធម៌សង្គម ........................................ ១៧

## V- ផលប្រយោជន៍ជាតិ និងអនាគតមាតុប្រទេស

1- ទ្រព្យសម្បត្តិជាតិ និងផលប្រយោជន៍រួម .................................. ១៨
2- បូរណភាពទឹកដី ................................................................... ២០
3- អន្តោប្រវេសន៍ខុសច្បាប់ .......................................................... ២១

# I- លទ្ធិប្រជាធិបតេយ្យ យុត្តិធម៌ និងសិទ្ធិមនុស្ស

## *1- លើកតំកើងលទ្ធិប្រជាធិបតេយ្យ*

១-រដ្ឋអំណាចត្រូវប្រកាន់គោលការណ៍ថ្មី អនុញ្ញាតអោយប្រជាពលរដ្ឋធ្វើអ្វីៗបានទាំងអស់ ដរាបណាគ្មានច្បាប់ហាមឃាត់ ។ ត្រូវបោះបង់ទំលាប់ និងស្មារតីចាស់ដែលអនុញ្ញាតអោយប្រជាពលរដ្ឋធ្វើអ្វីៗបាន លុះត្រាតែមានច្បាប់អនុញ្ញាត ។

២-ឈានពីប្រជាធិបតេយ្យដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែបោះឆ្នោតយូរៗម្តង ឆ្ពោះទៅប្រជាធិបតេយ្យ ដែលប្រជាពលរដ្ឋមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសំរេចគ្រប់បែបយ៉ាងទាក់ទងនឹងជីវភាពប្រចាំថ្ងៃរបស់ខ្លួន ។

៣-ជំរុញអោយមានលទ្ធភាពធ្វើប្រជាមតិ ដើម្បីផ្តល់ជូនប្រជារាស្ត្រនូវសិទ្ធិសំរេចដោយផ្ទាល់ លើបញ្ហាជាតិសំខាន់ៗ ។

៤-ជំរុញដំណើរការវិមជ្ឈការ គឺការផ្ទេរអំណាចពីថ្នាក់លើមកថ្នាក់ក្រោមអោយបានឆាប់រហ័ស ដើម្បីលើកតំកើងលទ្ធិប្រជាធិបតេយ្យ និងជីវភាពប្រជារាស្ត្រនៅមូលដ្ឋាន ។ តួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋានថ្នាក់ខេត្ត ស្រុក ឃុំ ភូមិ នឹងត្រូវកំណត់អោយបានច្បាស់លាស់ ស្របតាមស្មារតីវិមជ្ឈការដែលតំរូវអោយមានការបោះឆ្នោតគ្រប់ជាន់ថ្នាក់ ។

៥-រៀបចំសមាជជាតិរៀងរាល់ឆ្នាំ យោងតាមជំពូកទី ១២ នៃរដ្ឋធម្មនុញ្ញ ដោយមានព្រះរាជានុញ្ញាតពីព្រះមហាក្សត្រ ។ “សមាជជាតិបើកអោយប្រជារាស្ត្រជ្រាបដោយផ្ទាល់អំពីកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិ និងលើកបញ្ហា និង សំណូមពរជូនរដ្ឋអំណាចដោះស្រាយ” ។

៦-លុបបំបាត់ការបង្ខិតបង្ខំប្រជារាស្ត្រអោយចូលជាសមាជិក ឬចូលក្នុងរចនាសម្ព័ន្ធរបស់គណបក្សនយោបាយណាក៏ដោយ ។

៧-ធានា និងគោរពសិទ្ធិសេរីភាពរបស់ប្រជារាស្ត្រដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដូចជាសិទ្ធិបង្កើតសមាគម សិទ្ធិរួមប្រជុំ សិទ្ធិសំដែងមតិ សិទ្ធិធ្វើបាតុកម្ម សិទ្ធិផ្សព្វផ្សាយពត៌មាន ។ល។ ក្នុងចន្លោះពេលរង់ចាំច្បាប់លំអិត ។ ត្រូវរៀបចំអោយឆាប់រហ័សបំផុតនូវច្បាប់ស្តីពីការបង្កើត និងការគ្រប់គ្រងសមាគម ។

៨-ពិនិត្យឡើងវិញនូវសមាសភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីធានាអោយស្ថាប័ននេះមានតម្លាភាព ភាពសុក្រឹត និងមិនលំអៀង ក្នុងការរៀបចំរាល់ការបោះឆ្នោត ។

៩-រដ្ឋាភិបាលមិនចាំបាច់គ្រប់គ្រងអង្គការណា ដែលសង្គមស៊ីវិលអាចគ្រប់គ្រងបានដោយមានប្រសិទ្ធិភាពល្អប្រសើរជាង ដូចជាគណៈកម្មាធិការការពារសិទ្ធិមនុស្ស និងគណៈកម្មាធិការប្រឆាំងអំពើពុករលួយជាដើម ។

១០-រៀបចំអោយមានការអប់រំពីលទ្ធិប្រជាធិបតេយ្យ ដូចជា សិទ្ធិ និង កាតព្វកិច្ចប្រជា-ពលរដ្ឋនៅក្នុងកម្មវិធីសិក្សា ដើម្បីជំរុញការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំសង្គមអោយបានល្អប្រសើរ ។

១១- សមាជិកសភា មិនអាចត្រូវបណ្តេញចេញពីស្ថាប័ននីតិបញ្ញត្តិ ដោយមូលហេតុនយោបាយ ។ បេក្ខជនឯករាជ្យ អាចឈរឈ្មោះ ហើយអាចជាប់ឆ្នោតជាសមាជិកសភា ដោយមិនចាំបាច់ស្ថិតក្រោមផ្លាកគណបក្សនយោបាយណាឡើយ ។

១២-បុគ្គលម្នាក់អាចទទួលមុខតំណែងជានាយករដ្ឋមន្ត្រី ពីរអាណត្តិយ៉ាងច្រើន ទោះក្នុងកាលៈទេសៈណាក៏ដោយ មិនអាចលើសពី ១០ ឆ្នាំ ។

១៣-ការបំពេញមុខតំណែងថ្នាក់ខ្ពស់ ឬសំខាន់ៗ ក្នុងរដ្ឋបាលសាធារណៈ ត្រូវយកមកពិនិត្យរាល់ ៥ ឆ្នាំម្តងយ៉ាងយូរ ដើម្បីរៀបចំការប្តូរវេនជាធម្មតា ។

១៤-ជនជាតិខ្មែរដែលរស់នៅបរទេស នឹងទទួលបាននូវសិទ្ធិបោះឆ្នោត ដូចប្រជាពលរដ្ឋខ្មែរដែលរស់នៅប្រទេសកម្ពុជា ដោយមានការចាត់ចែងនីតិវិធី និងសំភារៈ អោយការបោះឆ្នោតប្រព្រឹត្តទៅបាន ក្នុងរាល់ប្រទេសដែលមានជនជាតិខ្មែររស់នៅច្រើន ។

## *2 - យុត្តិធម៌*

១៥-ធានាអោយប្រព័ន្ធតុលាការមានភាពឯករាជ្យ និងមិនពុករលួយ ដើម្បីផ្តល់យុត្តិធម៌ជូនប្រជារាស្ត្រ ។ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនត្រូវពាក់ព័ន្ធជាមួយក្រុមនយោបាយណាមួយ ហើយមិនត្រូវកាន់តំណែងផ្សេងទៀត ក្នុងស្ថាប័ននីតិប្រតិបត្តិ ឬនីតិបញ្ញត្តិឡើយ ។ ត្រូវរៀបចំច្បាប់មួយជាបន្ទាន់ ស្តីពីការបំពេញតួនាទី និងអាណត្តិរបស់ចៅក្រម និងព្រះរាជអាជ្ញា ។

១៦-ស្នើអង្គការសហប្រជាជាតិ រៀបចំតុលាការអន្តរជាតិ ស្ថិតនៅក្រៅប្រទេសកម្ពុជា ដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។

១៧-បញ្ចប់ទំលាប់អោយអ្នកមានអំណាចរួចទោស (និទណ្ឌភាព) ។ ស៊ើបអង្កេតយ៉ាងម៉ត់ចត់ពីបទឧក្រិដ្ឋ និងករណីរំលោភសិទ្ធិប្រជាពលរដ្ឋពីអតីតកាល ដើម្បីផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ។

## *3 - សិទ្ធិសេរីភាព និងសិទ្ធិមនុស្សជាទូទៅ*

១៨-ស្នើអង្គការសហប្រជាជាតិ បន្តឃ្លាំមើលស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា ហើយការពារសិទ្ធិមនុស្សរបស់ជនភៀសខ្លួននយោបាយពីប្រទេសជិតខាង ។

១៩-បែងចែករលកធាតុអាកាស អោយអ្នកត្រូវការផ្សព្វផ្សាយពតិមាន និងមតិតាមវិទ្យុ និងទូរទស្សន៍ដោយមិនលំអៀង ។ ច្បាប់សារពតិមានត្រូវគ្របដណ្តប់ប្រព័ន្ធវិទ្យុ និងទូរ-ទស្សន៍ផងដែរ ។ បង្កើត “អាជ្ញាធរជាតិ វិទ្យុ និងទូរទស្សន៍ ” ដែលមានភាពអព្យាក្រឹត និងឯករាជ្យ ដើម្បីគ្រប់គ្រងបញ្ហាបច្ចេកទេស និងខ្លឹមសារនៃការផ្សព្វផ្សាយ ។ វិទ្យុសំលេងសហរដ្ឋអាមេរិក និងវិទ្យុអាស៊ីសេរី នឹងត្រូវអនុញ្ញាតអោយមានស្ថានីយ៍ផ្សាយផ្ទាល់នៅកម្ពុជា ។

## *4 - សិទ្ធិព្រះសង្ឃ*

២០-ការពារសិទ្ធិព្រះសង្ឃក្នុងឋានៈព្រះអង្គជាប្រជាពលរដ្ឋ ដែលមានសិទ្ធិដូចប្រជាពលរដ្ឋដទៃទៀតដែរ ក្នុងការសំដែងមតិ ការចូលរួមប្រជុំ ការចូលរួមសមាគម និងការចូលរួមបោះឆ្នោត ។ ប្រគេនលទ្ធភាពព្រះសង្ឃអោយបានចូលរួមក្នុងកម្មវិធីសិក្សាក្នុងគ្រប់វិស័យ ព្រមទាំងការសិក្សានៅឯបរទេសផងដែរ ដោយពឹងផ្អែកលើវត្តអារាមរៀបចំដោយពុទ្ធបរិស័ទខ្មែរនៅឯនាយសមុទ្រ ។

## *5 - សិទ្ធិស្ត្រី*

២១-អនុវត្តវិធានការពិសេស ដើម្បីផ្តល់លទ្ធភាពអោយបានស្មើគ្នា រវាងស្ត្រី និងបុរសក្នុងការកសាងជីវិតរបស់ខ្លួន ។ គ្រួសារដែលមានកូនស្រីក្នុងបន្ទុក នឹងទទួលការឧបត្ថម្ភដើម្បីលើកទឹកចិត្តកូនស្រីនោះ អោយបានទៅរៀនសូត្រវែងឆ្ងាយដូចកូនប្រុសដែរ ។

យុវនារី ក៏នឹងទទួលការឧបត្ថម្ភ ដើម្បីលើកទឹកចិត្តអោយចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រយោជន៏រកការងារធ្វើបានងាយស្រួល ។

២២-ស្រ្តីដែលត្រូវការដើមទុនដើម្បីផ្តួចផ្តើមមុខរបរចិញ្ចឹមជីវិតដោយខ្លួនឯង នឹងទទួលបាននូវឥណទានពិសេស គឺប្រាក់អោយខ្ចី ពីស្ថាប័នឥណទានជាតិ ឬអង្គការសង្គមកិច្ចមួយទៀត ។

២៣-ក្រុមហ៊ុន សហគ្រាស ឬស្ថាប័នដទៃទៀត ដែលផ្តល់ការងារអោយពលករស្រ្តី នឹងទទួលបាននូវការលើកទឹកចិត្តពិសេសពីអាជ្ញាធរជាតិ ។

២៤-ស្រ្តីក្នុងគ្រួសារក្រីក្រដែលត្រូវការមធ្យោបាយពន្យារកំណើត នឹងទទួលការឧបត្ថម្ភពីអាជ្ញាធរជាតិក្នុងវិស័យនេះ ដោយមិនគិតថ្លៃ ។

# II- សន្តិសុខគ្រប់បែបយ៉ាងសំរាប់ប្រជារាស្រ្ត

## *1 - សន្តិសុខរាងកាយ*

២៥-បំបាត់អំពើហិង្សាគ្រប់បែបយ៉ាងនៅក្នុងសង្គម ។ សន្តិសុខ និងសន្តិភាពពិតប្រាកដសំរាប់ប្រជាពលរដ្ឋគ្រប់រូបស្ថិតជាចំបងលើមធ្យោបាយបង្ការ និងដោះស្រាយបញ្ហាសង្គមដូចជា ភាពក្រីក្រ ភាពគ្មានការងារធ្វើ និងភាពអស់សង្ឃឹម ដោយមិនចាំបាច់រំពឹងទាំងស្រុងលើតែវិធានការបង្រ្កាប និងដាក់ទណ្ឌកម្ម ។

២៦-ប្រយុទ្ធតទល់នឹងក្រុមម៉ាហ្វីយ៉ា ក្រុមឧក្រិដ្ឋជន និងក្រុមទុច្ចរិត ដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស សាស្រ្តាវុធ និងគ្រឿងញៀន ។ ក្នុងកិច្ចការនេះ រដ្ឋអំណាចត្រូវសហការយ៉ាងជិតស្និទ្ធជាមួយនឹងអង្គការអន្តរជាតិប្រឆាំងឧក្រិដ្ឋកម្ម ដូចជា ប៉ូលីសអាមេរិកកាំង (**FBI**) ក្រុមប្រឆាំងគ្រឿងញៀនអាមេរិកកាំង (**DEA**) និងប៉ូលីសអន្តរជាតិ (**Interpol**) ។

**២៧**-គ្រប់គ្រងការទុកដាក់ និងការប្រើប្រាស់គ្រឿងសព្វាវុធអោយមានប្រសិទ្ធិភាព ។ មានតែភ្នាក់ងារប៉ូលីស និងទាហានទេ ដែលមានសិទ្ធិកាន់អាវុធក្នុងពេលបំពេញបេសកកម្ម ស្របច្បាប់ និងច្បាស់លាស់ក្រោមការឃ្លាំមើលពីអាជ្ញាធរមានសមត្ថកិច្ច ។

**២៨**-បំបាត់ចោរកម្ម និងការជិះរិតគ្រប់បែបយ៉ាងតាមភូមិស្ថាន ព្រមទាំងតាមផ្លូវគោក ទន្លេ និងសមុទ្រ ។

**២៩**-បង្ការគ្រោះថ្នាក់ចរាចរ ដោយកែលំអប្រព័ន្ធផ្លូវថ្នល់ ធានាការគោរពច្បាប់ចរាចរ និងច្បាប់ប្រើប្រាស់យានយន្ត ព្រមទាំងពិនិត្យការចេញប័ណ្ណបើកបរ ហើយអប់រំសាធារណជនក្នុងការរក្សាសុវត្ថិភាព ។

**៣០**-ជួយសង្គ្រោះជនដែលទទួលគ្រោះថ្នាក់ចរាចរ អគ្គីភ័យ និងគ្រោះថ្នាក់ផ្សេងៗទៀត ដោយមធ្យោបាយមានប្រសិទ្ធិភាព ដូចជា រថយន្តសង្គ្រោះបន្ទាន់ រថយន្តអគ្គីភ័យ អមដោយអ្នកសង្គ្រោះដែលបានហ្វឹកហាត់ត្រឹមត្រូវ និងប្រដាប់ដោយសំភារៈទំនើប ។

### *2 - សន្តិសុខស្បៀងអាហារ*

**៣១**-ដើម្បីធានាសន្តិសុខស្បៀងអាហារ អាជ្ញាធរត្រូវរៀបចំឃ្លាំងអង្ករ និងស្បៀងផ្សេងៗទៀត ប្រយោជន៏ទប់ទល់ស្ថានការណ៏ខ្វះខាត ហើយត្រូវបន្ថយឥទ្ធិពលឈ្មួញកណ្តាលក្នុងការប្រមូល និងចែកចាយកសិផលតាមទីផ្សារ ។

**៣២**-អាជ្ញាធរគ្រប់គ្រងនិងដោះស្រាយគ្រោះមហន្តរាយ និងអង្គការកាកបាទក្រហមកម្ពុជា ត្រូវចែកស្បៀងអាហារ និងគ្រឿងប្រើប្រាស់ ជូនជនរងគ្រោះដោយមិនរើសមុខ និងមិនប្រកាន់បក្ខពួក។

### *3 - សន្តិសុខក្នុងការប្រើប្រាស់ទំនិញ*

៣៣-អាជ្ញាធរត្រូវធ្វើការត្រួតពិនិត្យយ៉ាងម៉ត់ចត់ និងទៀងទាត់ រាល់គ្រឿងឧបភោគបរិភោគ ដើម្បីធានាកុំអោយមានមេរោគ ឬជាតិពុល ហើយត្រូវធានាគុណភាព និងគោរពកាលបរិច្ឆេទប្រើប្រាស់នៃរាល់ទំនិញដែលដាក់លក់លើទីផ្សារ ដើម្បីការពារសុខភាព និងសុវត្ថិភាពប្រជាពលរដ្ឋ ។

៣៤-ជំរុញ និងជួយឧបត្ថម្ភអោយបង្កើត "សមាគមជាតិអ្នកប្រើប្រាស់" ប្រដាប់ដោយមន្ទីរពិសោធន៍ និងអមដោយអ្នកបច្ចេកទេសក្នុងជំនាញពាក់ព័ន្ធ ដើម្បីការពារសិទ្ធីអ្នកប្រើប្រាស់ទំនិញ ហើយធានាភាពសុចរិតមិនភូតកុហកនៃការផ្សព្វផ្សាយពាណិជ្ជកម្ម ។

## III- លើកតំកើងជីវភាពរស់នៅ

### *1- ប្រជារាស្ត្រទូទៅ*

៣៥-ប្រជារាស្ត្រតាមភូមិ-ឃុំ និងសហគមន៍តាមមូលដ្ឋាន មានសិទ្ធិសំរេចក្នុងការគ្រប់គ្រងដីធ្លី ព្រៃឈើ និងតំបន់នេសាទ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធានាការអភិវឌ្ឍន៍អោយបានយូរអង្វែង ដោយការពារទ្រព្យសម្បត្តិធម្មជាតិ និងបរិស្ថានអោយបានល្អត្រឹមត្រូវ ។

៣៦-ដោះស្រាយវិវាទដីធ្លីដែលមានសព្វថ្ងៃ រវាងអ្នកមានអំណាច និងប្រជារាស្ត្រតូចតាច ដោយជួយការពារសិទ្ធិស្របច្បាប់របស់ប្រជារាស្ត្រតូចតាច ដែលត្រូវបានអ្នកមានអំណាចរំលោភ ។

៣៧-បញ្ឈប់ការរឹបអូសយកដីធ្លីពីប្រជារាស្ត្រ និងការបណ្តេញប្រជារាស្ត្រពីដីធ្លី ដែលពួកគាត់បានរស់នៅយូរឆ្នាំមកហើយ ។ បើមានសំណើណាមួយអោយប្រជារាស្ត្រចាកចេញ

ពីដីធ្លីដែលពួកគាត់កំពុងតែរស់នៅ សំណើនោះត្រូវមានភ្ជាប់ជាមួយនូវសំណងដ៏សមរម្យ និងយុត្តិធមិជូនប្រជារាស្រ្ត ។ សំណងនោះ អាចជាដីធ្លីនៅទីកន្លែងណាមួយទៀតមានលក្ខណៈប្រហាក់ប្រហែលដីធ្លីដើម ឬជាថវិកាមានចំនួនប្រហាក់ប្រហែលតំលៃដីធ្លីដើម ។

៣៨-ពិនិត្យសើរើការរឹបអូសដីធ្លីរបស់ប្រជារាស្រ្តចាប់តាំងពីឆ្នាំ១៩៨៩ មកដល់សព្វថ្ងៃ ។ បើសិនជាការរឹបអូសនោះជាអំពើខុសច្បាប់ និងអយុត្តិធមិ ដីធ្លីនោះត្រូវប្រគល់សងជូនម្ចាស់ដើមស្របច្បាប់វិញ ។

៣៩-បញ្ឈប់ការរុះរើផ្ទះសំបែងប្រជារាស្រ្ត និងការបណ្តេញប្រជារាស្រ្តពីផ្ទះសំបែងដែលពួកគាត់បានរស់នៅយូរឆ្នាំមកហើយ ទោះជានៅតំបន់ណាក៏ដោយ ។ការរុះរើអាចធ្វើទៅបានលុះត្រាតែរដ្ឋអំណាចផ្តល់សំណងជូនប្រជារាស្រ្តអោយបានសមរម្យ និងយុត្តិធមិ ។ សំណងនោះអាចជា ផ្ទះសំបែងនៅទីកន្លែងណាមួយទៀតមានលក្ខណៈប្រហាក់ប្រហែលផ្ទះសំបែងដើម ឬជាថវិកាមានចំនួនប្រហាក់ប្រហែលតំលៃផ្ទះសំបែងដើម ។

៤០-រដ្ឋអំណាចនឹងរៀបចំលំនៅដ្ឋានសំរាប់ជនក្រីក្រ ដោយសាងសង់អាគារថ្មីនៅលើដីធ្លីរបស់រដ្ឋ ឬជួសជុល និងកែច្នៃអាគាររបស់រដ្ឋដែលមានស្រាប់ ។ លំនៅដ្ឋាននេះស្ថិតក្នុងកម្មវិធីសង្គមកិច្ច ហើយត្រូវដាក់ជួលក្នុងតំលៃទាប ឬអោយស្នាក់នៅដោយឥតគិតថ្លៃសំរាប់ជនក្រីក្រជាទីបំផុត ។

៤១-ហាមឃាត់មិនអោយមានសិទ្ធិផ្តាច់មុខ ក្នុងការប្រកបអាជីវកម្មផលិត និងចែកចាយអគ្គីសនី ។ នៅគ្រប់តំបន់ទាំងអស់ ប្រជាពលរដ្ឋមានសិទ្ធិរៀបចំជាសមាគម ដើម្បីផលិតនិងចែកចាយអគ្គិសនី ។ បើអគ្គិសនីត្រូវបានផលិតដោយក្រុមហ៊ុនឯកជនណាមួយ តំលៃអគ្គិសនីដែលដាក់លក់ជូនប្រជាពលរដ្ឋ មិនអាចលើសពីកំរិតមួយដែលកំណត់តាមការពិភាក្សាជាមួយអាជ្ញាធរមានសមត្ថកិច្ច និងតំណាងប្រជាពលរដ្ឋឡើយ ។

៤២-បញ្ចុះថ្លៃប្រេងសាំងពី ២៥០០ រៀលក្នុងមួយលីត្រ មកត្រឹមតែ ១៥០០ រៀលក្នុងមួយលីត្រ ក្នុងកាលៈទេសៈសព្វថ្ងៃ (ថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០០៣) គឺធ្វើយ៉ាងណាមិនអោយថ្លៃប្រេងសាំង និងប្រេងឥន្ទនៈផ្សេងទៀត មានកំរិតខ្ពស់ជាងនៅប្រទេសជិតខាងមានប្រទេសថៃជាដើម ។ វិធានការនេះជួយដល់ជីវភាពប្រជារាស្ត្រផង និងជួយលុបបំបាត់ការរត់ពន្ធខុសច្បាប់ផង ។

៤៣-លុបបំបាត់ការតំរូវអោយបង់ប្រាក់អោយក្រុមហ៊ុនឯកជន ក្នុងការប្រើប្រាស់ផ្លូវជាតិ និងផ្លូវថ្នល់នៅគ្រប់ខេត្ត-ក្រុង និងគ្រប់តំបន់ ។ ឧទាហរណ៍: ផ្លូវជាតិលេខ៤ ពីទីក្រុងភ្នំពេញ ទៅក្រុងព្រះសីហនុ ។

៤៤-ផ្តល់ជូនប្រជាពលរដ្ឋជាបន្ទាន់ដោយឥតគិតថ្លៃ នូវឯកសារផ្លូវការសំរាប់ការរស់នៅរាល់ថ្ងៃ ដូចជា អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ ប័ណ្ណស្នាក់នៅ និងលិខិតអនុញ្ញាតផ្សេងៗ ។

៤៥-រៀបចំប្រព័ន្ធសន្តិសុខសង្គមទូទាំងប្រទេស ដែលមានបំណងផ្តល់លទ្ធភាពអោយប្រជាពលរដ្ឋគ្រប់រូប ទប់ទល់រាល់ចំណាយចាំបាច់ទៅលើការថែទាំសុខភាព និងរក្សាសមត្ថភាពក្នុងការប្រកបការងារចិញ្ចឹមជីវិត ។

៤៦-ផ្តល់ការព្យាបាលជំងឺតាមលក្ខណៈវេជ្ជសាស្ត្រ (ពិនិត្យដោយគ្រូពេទ្យ និងផ្តល់ថ្នាំពេទ្យទំនើប) ចំពោះប្រជាពលរដ្ឋក្រីក្រគ្រប់រូប ដោយមិនគិតថ្លៃ ។

៤៧-ចែកចាយដល់រាល់សិស្សសាលា និងកូនក្មេងក្នុងគ្រួសារក្រីក្រ នូវចំណីអាហារបន្ថែមដែលមានជីវជាតិ និងធាតុផ្សេងទៀតចាំបាច់សំរាប់ការលូតលាស់របស់រាងកាយ និងខួរក្បាល និងសំរាប់រក្សាសុខភាពអោយបានល្អជាទូទៅ ។

៤៨-ផ្តល់លំនៅដ្ឋាន និងការឧបត្ថម្ភដល់ជនពិការ ដើម្បីធានាជីវភាពនៃជនពិការទាំងអស់អោយបានសមរម្យ និងថ្លៃថ្នូរ ។

## *2- ប្រជាកសិករ*

៤៩-ផ្តល់ប្លង់ដី និងប័ណ្ណកម្មសិទ្ធិដោយឥតគិតថ្លៃ ជូនប្រជាកសិករដែលមិនទាន់មានឯកសារទាំងនេះ ដើម្បីបញ្ជាក់ និងការពារកម្មសិទ្ធិលើដីធ្លី ដែលប្រជាកសិករទាំងនោះកំពុងតែគ្រប់គ្រងដើម្បីចិញ្ចឹមជីវិត ។ មិនយកពន្ធលើដីធ្លីរបស់ប្រជាកសិករ ។

៥០-កសាង ពង្រឹង ឬស្តារឡើងវិញ ប្រព័ន្ធធារាសាស្ត្រ (ប្រឡាយទឹក ទំនប់ទឹក ស្រះទ្វារទឹក ។ល។) ដើម្បីធានាអោយប្រជាកសិករមានទឹកគ្រប់គ្រាន់ធ្វើស្រែចំការក្នុងរដូវប្រាំង និងរដូវវស្សា ។

៥១-រកទីផ្សារជូនប្រជាកសិករ ដើម្បីលក់ផលដំណាំ ដូចជា ស្រូវ ពោត សណ្តែក ល្ង ថ្នាំជក់ ស្ករត្នោត ជ័រកៅស៊ូ ។ល។ ក្នុងតំលៃខ្ពស់សមរម្យ ដែលធ្វើអោយជីវភាពអ្នកធ្វើស្រែចំការបានធូរធារ ។ ក្នុងគោលដៅនេះ ត្រូវតែ :

- ផ្តល់សេរីភាពពេញលេញជូនអ្នកលក់ដូរ
- លុបបំបាត់សិទ្ធិផ្តាច់មុខ ឬលុបបំបាត់ការបង្ខំអោយលក់កសិផលក្នុងតំលៃទាប
- កាត់បន្ថយឥទ្ធិពលឈ្មួញកណ្តាល
- រៀបចំផ្លូវថ្នល់ និងមធ្យោបាយដឹកជញ្ជូនអោយបានល្អប្រសើរ
- រៀបចំប្រព័ន្ធសេរីប្រមូលកសិផលដើម្បីការពារផលប្រយោជន៏កសិករ
- ផ្តល់ពត៌មានជាក់ស្តែងពីតំលៃកសិផលលើទីផ្សារជាតិ និងអន្តរជាតិជូនចំពោះប្រជាកសិករ ។

**៥២**-ជួយការពារប្រជាកសិករដែលជំពាក់បំណុលអង្គការឥណទាន ហើយដែលគ្មានលទ្ធភាពបង់ការប្រាក់ ឬសងបំណុលដើមតាមការកំណត់ ដោយសារហេតុផលណាមួយដែលមិនអាចដឹងមុន ដូចជា ទឹកជំនន់ ភាពរាំងស្ងួត ជំងឺ ឬគ្រោះថ្នាក់ផ្សេងៗ ។ ជួយរកដំណោះស្រាយជាមួយអង្គការឥណទាន ដោយជៀសវាងមិនអោយមានការរឹបអូសយកដីស្រែ ឬផ្ទះសំបែងរបស់អ្នកជំពាក់បំណុល ។ បំណុលនោះត្រូវពន្យារ ឬកាត់បន្ថយ ។

### *3 - ប្រជានេសាទ*

**៥៣**-លុបចោលឡូត៍នេសាទពាណិជ្ជកម្មឯកជន ដែលគ្រប់គ្រងដោយនាយទុនធំៗ ។ ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់នេសាទ មានសិទ្ធិរៀបចំជាសហគមន៍នេសាទ ដើម្បីប្រកបមុខរបរនេសាទក្នុងលក្ខណៈគ្រួសារ ហើយជួយថែរក្សាមច្ឆជាតិ និងសម្បត្តិធម្មជាតិដទៃទៀត ។ ការរៀបចំជាសហគមន៍នេសាទនេះ ត្រូវធ្វើឡើងដោយការបោះឆ្នោតត្រឹមត្រូវ ពីព្រោះលទ្ធិប្រជាធិបតេយ្យ និងការរីកចំរើននៃជីវភាពរបស់អ្នកនេសាទតូចតាចតំរូវអោយប្រជារាស្ត្រមានសិទ្ធិគ្រប់គ្រងដោយខ្លួនឯងនូវតំបន់នេសាទ ក្រោមការមើលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច ។

### *4 - មន្ត្រីរាជការ គ្រូបង្រៀន ប៉ូលីស_ទាហាន*

**៥៤**-តំលើងប្រាក់ខែជូនមន្ត្រីរាជការគ្រប់រូប អោយបានយ៉ាងតិច ៤០ម៉ឺនរៀល (ឬ១០០ ដុល្លារ) ។ ប្រាក់បៀវត្សនេះ ត្រូវបើកអោយបានទៀងទាត់រៀងរាល់ខែ ។

**៥៥**-លើកទឹកចិត្តគ្រូពេទ្យ និងគ្រូបង្រៀនដែលស្ម័គ្រចិត្តទៅធ្វើការនៅតំបន់ដាច់ស្រយាលដោយផ្តល់ ប្រាក់កំរៃពិសេសបន្ថែមលើប្រាក់ខែធម្មតា ។ វិធានការនេះមានបំណងជួយថែទាំសុខភាពប្រជារាស្ត្រ និងជួយកូនចៅអ្នកស្រែចំការអោយបានរៀនសូត្រ ដូចកូនចៅអ្នកទីក្រុង ។

## 5 - កម្មករ និងនិយោជិត

**៥៦**-ជំរុញអោយសេដ្ឋកិច្ចលូតលាស់ដើម្បីបង្កើតការងារសំរាប់យុវជន ដែលដល់អាយុរកការងារធ្វើ ចំនួនប្រមាណ២០ម៉ឺននាក់ក្នុងមួយឆ្នាំ ។ ការបង្កើតការងារនេះ អាស្រ័យលើការលើកទឹកចិត្តអ្នកវិនិយោគខ្មែរ និងបរទេស អោយបង្កើតសហគ្រាស រោងចក្រ និងសកម្មភាពផ្សេងៗ ដើម្បីស្រូបយកពលករដែលនៅទំនេរ អោយបានចូលធ្វើការគ្រប់គ្នា ។ វិនិយោគនឹងកើនឡើង ក្រោយពីយើងបំបាត់អំពើពុករលួយ និងបង្កលក្ខណៈងាយស្រួលដល់ការប្រកបអាជីវកម្មស្របច្បាប់ ។ ក្នុងគោលបំណងនេះ យើងត្រូវធានាជូនអ្នកវិនិយោគនូវ :

- សន្តិសុខរាងកាយ
- សន្តិសុខផ្លូវច្បាប់ (ដូចជា ការគោរពកិច្ចសន្យា)
- ការរៀបចំអោយមានតុលាការឯករាជ្យ និងយុត្តិធម៌
- ការកសាងហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ ទឹក ភ្លើង ទូរស័ព្ទ ។ល។) អោយមានភាពទំនើប
- ការបណ្តុះបណ្តាលពលករតាមសេចក្តីត្រូវការរបស់អ្នកវិនិយោគ ។

**៥៧**-តំលើងប្រាក់ខែជូនកម្មកររោងចក្រ និងបុគ្គលិកក្រុមហ៊ុន អោយបានយ៉ាងតិច ២៨ម៉ឺនរៀល(ឬ៧០ដុល្លារ)ដោយធ្វើការតែ ៤៤ ម៉ោងក្នុងមួយសប្តាហ៍ ។ ម៉ោងពេលធ្វើការលើសពីនេះ ត្រូវគិតតាមតំលៃថែមម៉ោង យោងតាមច្បាប់ការងារ ។

**៥៨**-ជំរុញអោយបង្កើតតុលាការការងារអោយបានឆាប់រហ័ស ដូចមានចែងក្នុងច្បាប់ការងារ ដើម្បីដោះស្រាយវិវាទ រវាងនិយោជិត និងនិយោជក ។ ក្នុងពេលឥឡូវនេះត្រូវធានា

អោយក្រុមប្រឹក្សាអាជ្ញាកណ្តាលមានភាពឯករាជ្យ ដើម្បីដោះស្រាយវិវាទការងាររវាងកម្មករ និងថៅកែរោងចក្រ ប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌ ។

## *6- កម្មករចំការកៅស៊ូ និងម្ចាស់ចំការកៅស៊ូជាលក្ខណៈគ្រួសារ*

**៥៩**-ផ្ទេរការគ្រប់គ្រងចំការកៅស៊ូពីរដ្ឋទៅឯកជន ។ ការផ្ទេរនេះត្រូវធ្វើតាមរបៀបដេញថ្លៃប្រកបដោយតំលាភាព ហើយដោយគោរពលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅបន្ទុក ។ ចំការកៅស៊ូទំហំតូចជាលក្ខណៈគ្រួសារ ត្រូវទទួលការលើកទឹកចិត្តពីរដ្ឋអំណាច ។ ផលិតផលជ័រកៅស៊ូត្រូវមានសិទ្ធិដឹកជញ្ជូន និង លក់ដូរដោយសេរីក្នុងប្រទេស ។ ផលិតផលជ័រកៅស៊ូ អាចធ្វើការនាំចេញយកទៅលក់នៅក្រៅប្រទេសបាន ក្រោយពីបានបង់ពន្ធជូនរដ្ឋត្រឹមត្រូវ ។

**៦០**-លើកតំកើងជីវភាពកម្មករចៀរជ័រកៅស៊ូនៅតាមមូលដ្ឋាននានាទូទាំងប្រទេសអោយមានកំរិតប្រាក់ខែសមរម្យ មានលំនៅដ្ឋានត្រឹមត្រូវ មានអនាម័យនិងការថែទាំសុខភាព (មណ្ឌលសុខភាព គ្រូពេទ្យ ថ្នាំសង្កូវ) ។ កម្មករចំការកៅស៊ូមានសិទ្ធិរៀបចំសហជីពសេរីដើម្បីការពារផលប្រយោជន៍របស់ខ្លួន ដូចពលករដទៃទៀតនៅក្នុងប្រទេសសេរី និងជឿនលឿន។ កូនចៅរបស់កម្មករចំការកៅស៊ូទាំងអស់ ត្រូវធានាអោយបានចូលរៀនត្រឹមត្រូវ ។

## *7- អាជីវករ និងអ្នកលក់ដូរតូចតាច*

**៦១**-បញ្ឈប់ការបណ្តេញ ឬការបង្ខំអោយរុះរើតូបរបស់អ្នកលក់ដូរតូចតាចនៅតាមទីផ្សារគ្រប់ខេត្ត-ក្រុង ។ ការសាងសង់អាគារថ្មីដើម្បីជំនួសទីផ្សារសព្វថ្ងៃ អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអ្នកលក់ដូរសព្វថ្ងៃ នៅតាមទីផ្សារនីមួយៗ ។ ការយល់ព្រមនេះត្រូវផ្អែកលើលក្ខណៈបច្ចេកទេសនៃអាគារថ្មីដែលគ្រោងសាងសង់ ព្រមទាំងលើតំលៃនៃ

ាន ឬតូបដែលគ្រោងដាក់លក់ ឬជួល នៅក្នុងអាគារថ្មី ។ ត្រូវបញ្ចុះពន្ធដារ និងភាសីផ្សារ ដែលប្រមូលពីអ្នកលក់ដូរតូចតាច ។

### *8 - អ្នករត់ម៉ូតូឌុប និងតាក់ស៊ី*

៦២-លុបបំបាត់ពន្ធដារ និងការជំរិតទារប្រាក់គ្រប់ប្រភេទ ពីអ្នករត់តាក់ស៊ី អ្នករត់រ៉ឺម៉ក អ្នកបររទេះ និងអ្នករត់ម៉ូតូឌុបនៅទូទាំងប្រទេស ។

### *9 - អតីតយុទ្ធជន*

៦៣-ផ្តល់ការឧបត្ថម្ភទៀងទាត់ ឬប្រាក់បំណាច់សមរម្យដល់យោធាដែលត្រូវរំសាយ ។ កម្មវិធីរំសាយកងទ័ព និងកម្មវិធីជួយទ្រទ្រង់ជីវភាពយោធាដែលត្រូវរំសាយ នឹងប្រព្រឹត្តទៅដោយលុបបំបាត់អំពើពុករលួយ និងអំពើអយុត្តិធមិមកលើអតីតយុទ្ធជន ។ រដ្ឋអំណាចត្រូវបន្តជួយទាហានដែលបានរំសាយ ក្នុងការរកការងារថ្មីដើម្បីចិញ្ចឹមជីវិត ក្នុងវិស័យកសិកម្ម សិប្បកម្ម ឬពាណិជ្ជកម្ម ។

៦៤-ទាហានដែលបានរំសាយ រក្សាបាននូវសិទ្ធិរបស់ខ្លួនជានិច្ចជាអតីតយុទ្ធជន ដែលបានបំរើនិងការពារជាតិ ហើយជាតិក៏មិនអាចបំភ្លេចគុណបំណាច់របស់អតីតយុទ្ធជនទាំងអស់នោះ ទោះជាធ្លាប់បានប្រកាន់និន្នាការនយោបាយខាងណាក៏ដោយ ។

### *10 - សិស្ស និងនិស្សិត*

៦៥-ធានាអោយកូនខ្មែរគ្រប់រូបបានចូលរៀនគ្រប់ម៉ោងពេល ក្នុងប្រព័ន្ធអប់រំរបស់រដ្ឋ ពីបឋមសិក្សា ដល់មធ្យមសិក្សា ដោយមិនចាំបាច់បង់ថ្លៃ ។

៦៦-រៀបចំសាងសង់ និងគ្រប់គ្រងបុរីនិស្សិតនៅតាមទីក្រុងដែលមានមហាវិទ្យាល័យ ដើម្បីជាកន្លែងស្នាក់នៅ ដោយគិតថ្លៃជួលទាបបំផុត សំរាប់និស្សិតដែលមកពីជនបទ ។

៦៧-រៀបចំប្រព័ន្ធអាហារូបករណ៍ (ការឧបត្ថម្ភដល់សិស្ស និងនិស្សិត) សំរាប់ជួយសិស្ស និងនិស្សិតមកពីគ្រួសារក្រីក្រ ដែលមានសមត្ថភាពសិក្សាបានវែងឆ្ងាយ អោយមានលទ្ធភាព បំពេញការសិក្សាដល់កំរិតខ្ពស់ជាអតិបរមា ។

៦៨-បង្កើនលទ្ធភាពអោយនិស្សិតខ្មែរ បានទៅសិក្សានៅបរទេស គ្រប់មុខជំនាញរយៈពេលយូរឆ្នាំ ។ ចរចាជាមួយប្រទេសម្ចាស់ជំនួយ អោយផ្ទេរជំនួយមួយផ្នែកសំរាប់ប្រើប្រាស់ក្នុងការរៀបចំកម្មវិធីបញ្ជូននិស្សិតខ្មែរ ទៅសិក្សានៅបស្ចឹមប្រទេស ។

# IV- រដ្ឋាភិបាលស្អាតស្អំ ប្រកបដោយប្រសិទ្ធភាព

## *1 - ប្រឆាំងអំពើពុករលួយ*

៦៩-អនុម័ត និងអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ ហើយបង្កើតគណៈកម្មាធិការជាតិប្រឆាំងអំពើពុករលួយ ។

៧០-តំរូវអោយសមាជិករដ្ឋាភិបាល និងមន្ត្រីរាជការជាន់ខ្ពស់ ប្រកាសទ្រព្យសម្បត្តិរបស់ខ្លួន ហើយបញ្ជាក់អំពីប្រភពនៃទ្រព្យសម្បត្តិទាំងនោះ ។

៧១-ពិនិត្យសើរើសមាសភាពអាជ្ញាធរអគ្គសវនកម្មជាតិ ដើម្បីធ្វើអោយស្ថាប័ននេះមានភាពឯករាជ្យ និងមានប្រសិទ្ធភាព ក្នុងការលាតត្រដាងអំពើពុករលួយ ។

៧២-ទាមទារប្រាក់ដែលជនពុករលួយនៅប្រទេសកម្ពុជា បានយកទៅតំកល់លាក់ទុកនៅឯបរទេស យកមកសងប្រជារាស្ត្រខ្មែរវិញ ។ ក្នុងគោលបំណងនេះ រដ្ឋាភិបាល សម រង្ស៊ី នឹងចូលរួមក្នុងការរៀបចំច្បាប់ធនាគារអន្តរជាតិជាមួយប្រទេសដទៃទៀត ដើម្បីតាមដានប្រាក់ដែលបានមកពីអំពើពុករលួយ ឬពីសកម្មភាពខុសច្បាប់ដទៃទៀត ។

**៧៣**-រៀបចំបញ្ជីសារពើភ័ណ្ឌដីធ្លីនៅទូទាំងប្រទេស ដើម្បីសំគាល់ដីធ្លីរបស់រដ្ឋដែលនៅទំនេរ ឬដែលត្រូវជនផ្តាច់ការ និងពុករលួយបានយកទៅគ្រប់គ្រង ឬធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនដោយខុសច្បាប់ ។ បញ្ជីសារពើភ័ណ្ឌដីធ្លីនេះ ត្រូវអោយមានសូរិយោដីទំនើប ហើយជាមូលដ្ឋាននៃកំណែទំរង់ភូមិបាល ដែលនឹងជួយធ្វើអោយប្រទេសរីកចំរើនក្នុងយុត្តិធមិសង្គម ។

**៧៤**-ផ្អាកទុករយៈពេលមួយឆ្នាំ ការលក់ដូរដីធ្លីណាដែលពាក់ពន្ធ័នឹងទ្រព្យសម្បត្តិរដ្ឋ ដើម្បីធ្វើការស៊ើបអង្កេត និងវាយតំលៃត្រឹមត្រូវ ។

## *2- យុត្តិធម៌សង្គម*

**៧៥**-ធ្វើការស៊ើបអង្កេតលើលិខិតស្នាមគ្រប់គ្រងដីធ្លី ដែលមានទំហំចាប់ពី ១00 ហិកតាឡើងទៅ ដើម្បីបញ្ជាក់អំពីសិទ្ធិកាន់កាប់ស្របច្បាប់ ក្នុងគោលបំណងការពារទ្រព្យសម្បត្តិរដ្ឋ និងបែងចែកដីធ្លីជូនប្រជារាស្ត្រក្រីក្រ ។

**៧៦**-អនុវត្តអោយបានត្រឹមត្រូវ ច្បាប់ពន្ធដារដែលកំណត់យកពន្ធ ១0 ភាគរយ លើប្រាក់ឈ្នួលផ្ទះវីឡា ឬអាគារដទៃទៀត ដែលផ្តល់តំលៃឈ្នួលចាប់ពី ១000 ដុល្លារអាមេរិកក្នុងមួយខែឡើងទៅ ។

**៧៧**-កំណត់យកពន្ធលើទ្រព្យសម្បត្តិ ចំពោះបុគ្គលណាដែលមានទ្រព្យសម្បត្តិមានតំលៃចាប់ពី ៥0ម៉ឺនដុល្លារអាមេរិកឡើងទៅ ។

**៧៨**-ធានាការចែកចាយជំនួយមនុស្សធមិអន្តរជាតិ អោយបានដល់ដៃប្រជារាស្ត្រខ្វះខាតគ្រប់រូបដោយមិនប្រកាន់បក្ខពួក ។

## 3- អភិបាលកិច្ចល្អ និងសីលធម៌សង្គម

**៧៩**-ធានាការបែងចែកច្បាស់លាស់រវាងរដ្ឋគ្រប់គ្រងប្រទេស និងគណបក្សកំពុងកាន់អំណាច ហើយរារាំងការបង្វែរប្រាក់ចំណូលរបស់រដ្ឋ ទៅអោយគណបក្សកាន់អំណាច ។

**៨០**-រដ្ឋបាលសាធារណៈគ្រប់ជាន់ថ្នាក់ ទាំងស៊ីវិល ទាំងយោធា ត្រូវមានភាពមិនលំអៀង ដើម្បីបំរើ និងការពារប្រជាពលរដ្ឋទូទៅ ដោយមិនប្រកាន់បក្ខពួក ។ រដ្ឋាភិបាល សម រង្ស៊ី រក្សាទុកដដែល មន្ត្រីរាជការទាំងអស់ ដែលបំរើជាតិក្នុងស្មារតីខាងលើនេះ ទោះជាមន្ត្រីរាជការទាំងនោះ ធ្លាប់បានគាំទ្រគណបក្សនយោបាយណាក៏ដោយ ។

**៨១**-ហាមស្ថាប័នរដ្ឋធ្វើពាណិជ្ជកម្ម ក្នុងវិស័យណាដែលឯកជនធ្វើបានល្អប្រសើរ ដោយមានការប្រកួតប្រជែងត្រឹមត្រូវ ដូចជាទូរស័ព្ទ ទេសចរណ៍ ការដឹកជញ្ជូន ធានារ៉ាប់រង ។

**៨២**-ហាមឃាត់ស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិ រួមទាំងកងកំលាំងប្រដាប់អាវុធផងដែរ មិនអោយប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ដើម្បីប្រកបអាជីវកម្ម ដែលស្ថិតនៅក្រៅភារកិច្ចរបស់ខ្លួន ។

**៨៣**-រៀបចំច្បាប់ប្រឆាំងសិទ្ធិផ្តាច់មុខក្នុងរាល់មុខរបរ និងបង្ក្រាបសកម្មភាពរារាំងការប្រកួតប្រជែងពាណិជ្ជកម្ម ។ ត្រូវហាមឃាត់មិនអោយគណបក្សនយោបាយ ឬអ្នកនយោបាយ និងបក្ខពួក ប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន ដណ្តើមឯកសិទ្ធិ យកប្រៀបលើអ្នកប្រកួតប្រជែងដទៃទៀត ។

**៨៤**-ត្រូវសំរេចជ្រើសរើសអ្នកផ្គត់ផ្គង់ស្ថាប័នរដ្ឋ ជាសំភារៈ ឬជាសេវា តាមរយៈការដេញថ្លៃជាចំហ ប្រកបដោយតំលាភាព ។ ត្រូវលើកតំកើងការប្រជែងដេញថ្លៃពិតប្រាកដ ហើយលើកទឹកចិត្តអោយមានពាណិជ្ជករថ្មី និងច្រើនមកចូលរួម ។

**៨៥**-កាត់បន្ថយការបង្កើតកាស៊ីណូ និងបនល្បែងស៊ីសង ដែលនាំមកនូវវិបត្តិសង្គម ដូចជា ការលួចប្លន់ ការចាប់ជំរិត អំពើហិង្សា និងអំពើពាលាអាវ៉ាសែ ។

## V- ផលប្រយោជន៍ជាតិ និងអនាគតមាតុប្រទេស

### *1 - ទ្រព្យសម្បត្តិជាតិ និងផលប្រយោជន៍រួម*

**៨៦**-អនុវត្តមាត្រា ៥៨ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា ទ្រព្យសម្បត្តិរបស់រដ្ឋ មានជាអាទិ៍ ដីធ្លី..... ភ្នំ សមុទ្រ..... ឆ្នេរសមុទ្រ កោះ ស្ទឹង បឹង និងព្រៃឈើ..... ។ ដូច្នេះ ការរំលោភលើទ្រព្យសម្បត្តិរដ្ឋទាំងប៉ុន្មាន ត្រូវផ្តន្ទាទោស ។

**៨៧**-រៀបចំបញ្ជីសារពើភ័ណ្ឌព្រៃឈើដែលនៅសេសសល់ ដោយប្រើមធ្យោបាយបច្ចេកទេសទំនើបបំផុត (រូបថតពីយន្តហោះ រូបថតពីផ្កាយរណប និងប្រព័ន្ធអេឡិចត្រូនិចសំគាល់ចំណុចទីតាំង) ដើម្បីគ្រប់គ្រង និងការពារព្រៃឈើទាំងនោះ អោយបានត្រឹមត្រូវ ហើយការពារបរិស្ថានជាទូទៅផងដែរ ។

**៨៨**-ពិនិត្យឡើងវិញ ឬលុបចោលតែម្តងកិច្ចសន្យាសម្បទានព្រៃឈើ ដែលរដ្ឋាភិបាលមុនបានផ្តល់អោយក្រុមហ៊ុនឯកជន ហើយចាត់វិធានការផ្សេងទៀត ដើម្បីបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ ។

**៨៩**-អនុវត្តកម្មវិធីដាំដើមឈើឡើងវិញ ក្នុងទ្រង់ទ្រាយធំ ដោយមានការថែទាំជាប្រចាំ ដើម្បីពង្រីកទំហំព្រៃឈើឡើងវិញ នៅទូទាំងប្រទេសកម្ពុជា ហើយស្តារប្រព័ន្ធបរិស្ថានឡើងវិញ ប្រយោជន៍ជៀសវាងគ្រោះធម្មជាតិ ដូចជា ទឹកជំនន់ និងភាពរាំងស្ងួត ។

៩០-អនុវត្តកម្មវិធីការពារធនធានធម្មជាតិដទៃទៀត ដូចជា ត្រី សត្វព្រៃ រ៉ែគ្រប់ប្រភេទ ។ លើកទឹកចិត្តអង្គការ ឬ សមាគម ដែលមានបេសកកម្មថែរក្សាប្រភេទត្រី និងសត្វព្រៃ ដែលជិតផុតពូជ ។

៩១-ស្តារបឹង ទន្លេ ព្រែក អូរ ស្រះ ក្នុងគោលបំណងផ្ទុកទឹកអោយបានច្រើនហើយនៅបានយូរ ដើម្បីបង្ការទឹកជំនន់ បង្កើនលទ្ធភាពស្រោចស្រពដំណាំ ផ្គត់ផ្គង់ទឹកប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ ព្រមទាំងបង្កើនធនធានត្រី និង សំរួលការធ្វើដំណើរតាមផ្លូវទឹក ។

៩២-ការពារ និងថែរក្សាវត្ថុបុរាណ និងសម្បត្តិវប្បធម៌ ដោយបង្ក្រាបអំពើលួចប្លន់ និងជួញដូរវត្ថុបុរាណ ។ បញ្ឈប់ការទន្ទ្រានលើបរិវេណប្រាសាទបុរាណ ក្នុងគោលបំណង ធ្វើពាណិជ្ជកម្មផ្ទុយពីផលប្រយោជន៍រួម ។

៩៣-សើរើការធ្វើអាជីវកម្មលើបេតិកភណ្ឌជាតិ (ដូចជា ប្រាសាទអង្គរវត្ត និងភ្នំគូលេន នៅខេត្តសៀមរាប) ដោយក្រុមហ៊ុនឯកជន ឬបុគ្គលទុច្ចរិត ដែលឆ្លៀតឱកាសកេងប្រវ័ញ្ចទ្រព្យសម្បត្តិជាតិ ហើយប្រើវិធីចែកអំណោយបន្តិចបន្តួច ដើម្បីបំភាន់ភ្នែកប្រជារាស្ត្រ ។

៩៤-ពិនិត្យឡើងវិញរាល់កិច្ចសន្យាសាធារណៈ ដើម្បីបញ្ជាក់អំពីភាពស្របច្បាប់ ប្រឆាំងអំពើពុករលួយ និងការពារផលប្រយោជន៍ជាតិ ។ កិច្ចសន្យាណាមិនសមស្របនឹងត្រូវកែតំរូវ ឬលុបចោល ។ ឧទាហរណ៍ :

-កិច្ចសន្យាប្រគល់ដីបរិវេណពហុកីឡាដ្ឋានជាតិអូឡាំពិក នៅទីក្រុងភ្នំពេញអោយទៅក្រុមហ៊ុនឯកជនបរទេស សាងសង់អាគារ ពាណិជ្ជកម្ម ឬសំណង់ផ្សេងទៀតសំរាប់ដាក់លក់ ឬដាក់ជួល ដោយគ្មានការយល់ព្រម ពីប្រជាពលរដ្ឋ ជាពិសេសកីឡាករដែលប្រើប្រាស់ពហុកីឡាដ្ឋានជាតិអូឡាំពិក ដែលជាទ្រព្យសម្បត្តិជាតិ ។

- កិច្ចសន្យាជាមួយថៃ ស្តីពីការងារខួងអណ្តូងប្រេងកាត ក្នុងដែនសមុទ្រ

- កិច្ចសន្យាលក់ ឬជួលទ្រព្យសម្បត្តិរដ្ឋដទៃទៀត ដូចជាការលក់ទីធ្លាអតីតមន្ទីរពេទ្យចិន ពន្ធនាគារតេ៣ និងដីបឹងនៅជាប់ផ្លូវរទេះភ្លើង (ខាងត្បូងវត្តនាគវន្ត) នៅទីក្រុងភ្នំពេញ ។ល ។

## *2 - បូរណភាពទឹកដី*

**៩៥**-ទាមទារលុបចោលសន្ធិសញ្ញាព្រំដែន ដែលរដ្ឋអំណាចសម័យមុន បានចុះហត្ថលេខាជាមួយប្រទេសវៀតណាម កាលពីឆ្នាំ ១៩៧៩ ១៩៨២ ១៩៨៣ និង ១៩៨៥ ធ្វើអោយប្រទេសកម្ពុជាបាត់បង់ទឹកដីជាច្រើន ។ សន្ធិសញ្ញានេះរំលោភកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ១៩៩១ ស្តីអំពីអធិបតេយ្យភាព ឯករាជភាព និងបូរណភាពទឹកដីប្រទេសកម្ពុជា ។

**៩៦**-ស្នើកោះប្រជុំឡើងវិញ សន្និសីទទីក្រុងប៉ារីសស្តីពីសន្តិភាពនៅកម្ពុជា ដើម្បីទាមទារអោយមានការគោរពត្រឹមត្រូវ ចំពោះកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ១៩៩១ ទាក់ទងទៅនឹងការធានាបូរណភាពទឹកដីប្រទេសកម្ពុជា ។

**៩៧**-ខិតខំខ្នះខ្នែងតាមគ្រប់មធ្យោបាយសន្តិវិធី ទាមទារជូនប្រទេសកម្ពុជាវិញ នូវទឹកដីដែលប្រទេសជិតខាងបានលួចយកដោយខុសច្បាប់ ។ តំរូវអោយប្រទេសជិតខាងគោរពព្រំដែនប្រទេសកម្ពុជា ដូចដែលពិភពលោកទាំងមូលបានទទួលស្គាល់នៅឆ្នាំ ១៩៦៧-១៩៦៨ ក្នុងសម័យសង្គមរាស្ត្រនិយម ។

**៩៨**-តវ៉ាតាមផ្លូវទូតយ៉ាងម៉ឺងម៉ាត់បំផុត ចំពោះរាល់ការរំលោភដែនគោក ដែនទឹក និងដែនអាកាសរបស់ប្រទេសកម្ពុជា ពីសំណាក់ប្រទេសជិតខាង ហើយលើកយកបញ្ហាព្រំដែននេះ អោយសហគមន៍អន្តរជាតិ និងអង្គការសហប្រជាជាតិជួយដោះស្រាយ ។ ផ្តល់

បញ្ជាយ៉ាងច្បាស់លាស់ដល់យោធា និងប៉ូលីសនៅតាមព្រំដែន អោយការពារទឹកដីប្រទេសយើងយ៉ាងម៉ឺងម៉ាត់ ។

**៩៩**-អនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទ ដោយផ្តល់អាទិភាពពិសេសដល់តំបន់ជាប់ព្រំប្រទល់ដែន ។ ការកសាងផ្លូវថ្នល់ និង រាល់វិធានការ ដើម្បីលើកស្ទួយជីវភាពប្រជារាស្ត្រនៅតំបន់ព្រំដែន ជាផ្នែកមួយនៃការការពារបូរណភាពទឹកដី ។

### *3- អន្តោប្រវេសន៍ខុសច្បាប់*

១00-អនុវត្តច្បាប់សញ្ជាតិ និងច្បាប់អន្តោប្រវេសន៍អោយបានត្រឹមត្រូវដើម្បីដោះស្រាយបញ្ហាអន្តោប្រវេសន៍ខុសច្បាប់ ។ ទប់ស្កាត់មិនអោយជនបរទេសបន្លំធ្វើជាខ្មែរ ដោយប្រើប្រាស់ឯកសារខុសច្បាប់ ដើម្បីមានសិទ្ធិគ្រប់បែបយ៉ាងដូចប្រជាពលរដ្ឋខ្មែរ ។ ជនបរទេសអាចទទួលសិទ្ធិរស់នៅក្នុងប្រទេសកម្ពុជា តែសិទ្ធិរស់នៅនេះ ត្រូវបញ្ជាក់ដោយឯកសារដោយឡែក ដាច់ស្រឡះពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

## ❖ ខ្ញុំបោះឆ្នោតអោយគណបក្ស សម រង្ស៊ី ពីព្រោះ :

១- គណបក្ស សម រង្ស៊ី នឹងធ្វើអោយជីវភាពខ្ញុំរីកចំរើន ដោយបំបាត់អំពើពុករលួយ ហើយផ្តល់យុត្តិធម៌ឱ្យខ្ញុំ

២- គណបក្ស សម រង្ស៊ី ការពារទឹកដីខ្មែរ និងផលប្រយោជន៍ជាតិ

៣- សម រង្ស៊ី និងបេក្ខជនគណបក្ស សម រង្ស៊ី ជាអ្នកដឹកនាំក្លាហាន ស្អាតស្អំ និងមានសមត្ថភាព

## ❖ ខ្ញុំមិនបោះឆ្នោតអោយគណបក្សដទៃ ពីព្រោះ :

១- យើងរស់នៅក្នុងភាពក្រីក្រ និងរងទុក្ខវេទនាយូរឆ្នាំមកហើយ ដោយសារអំពើពុករលួយ នៃមេដឹកនាំផ្តាច់ការ និងពួករណប

២- មេដឹកនាំសព្វថ្ងៃមិនការពារទឹកដីខ្មែរ និងផលប្រយោជន៍ជាតិ

៣- សន្លឹកឆ្នោតខ្ញុំនឹងខាតបង់ ប្រសិនបើខ្ញុំបោះឆ្នោតឱ្យគណបក្សតូចៗ

វិធានការ ១០០ នៃគណបក្ស សម រង្ស៊ី បានត្រូវអនុម័ត
ដោយសមាជសាមញ្ញគណបក្ស សម រង្ស៊ី លើកទី ៣
ថ្ងៃទី២៨-២៩ ខែមីនា ឆ្នាំ២០០៣

---

គណបក្ស សម រង្ស៊ី ផ្ទះលេខ៧១ មហាវិថីសម្ដេចសុធារស រាជធានីភ្នំពេញ
ទូរសព្ទ័ / ទូរសារៈ ០២៣ ២១៧ ៤៥២ - ០២៣ ២១១ ៣៣៦
E-mail: samrainsycabinet@forum.org.kh Website: www.samrainsyparty.org

**តម្លៃ ៥០០ រៀល**